ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......សហវ.....

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារ
## នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៣៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង ស្ថាប័នថវិកាកម្មវិធី
- យោងតាមការចំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.–**

ត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មូលនិធិ នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានចែងក្នុងឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.–**

អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចរៀបចំបង្កើតបន្ថែមនូវលេខកូដចំណាត់ថ្នាក់មូលនិធិតាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំនៅក្នុងប្រព័ន្ធ FMIS ហើយនៅចុងឆ្នាំនីមួយៗ ត្រូវរៀបចំប្រកាសបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់មូលនិធិដែលបានបង្កើតបន្ថែម ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងចុះហត្ថលេខាលើប្រកាសបំពេញបន្ថែម។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.–**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  *"ដើម្បីជូនជ្រាប"*
- គ្រប់ក្រសួង ស្ថាប័ន
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៧៣២.. ចុះថ្ងៃទី ១៤. ខែ កក្កដា ឆ្នាំ ២០១៧

# ចំណាត់ថ្នាក់មូលនិធិ នៃមាតិកាថវិកា

| លេខកូដ | បរិយាយ |
|---|---|
| 1 | ហិរញ្ញប្បទានក្នុងស្រុក |
| 11 | មូលនិធិទូទៅ |
| 12 | សេវាបំណុល |
| 13 | សន្តិសុខសង្គម-សោធន៍និវត្ត |
| 14 | ថវិកាបដិភាគ |
| 2 | ហិរញ្ញប្បទានឥតសំណង (Grant) |
| 21 | មូលនិធិពិសេស (Special Fund) |
| 211 | ដៃគូអភិវឌ្ឍន៍ពហុភាគី (Multilateral Development Partners) |
| 21101 | ធនាគារពិភពលោក (WB) |
| 21102 | ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) |
| 21103 | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) |
| 21104 | សហភាពអឺរ៉ុប (EU) |
| 21105 | មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIF) |
| 21106 | ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) |
| 21107 | មូលនិធិអភិវឌ្ឍន៍ណ័រឌីក (NDF) |
| 21108 | មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) |
| 21109 | អង្គការ សមាគម សហព័ន្ធអន្តរជាតិផ្សេងៗទៀត |
| 21110 | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) |
| 21111 | អង្គការ UNICEF (United Nations Children's Fund) |
| 21112 | អង្គការ UNCDF (United Nations Capital Development Fund) |
| 21113 | អង្គការ FAO (Food and Agriculture Organisation of the United Nations) |
| 21114 | អង្គការ ILO (International Labor Organisation) |
| 21115 | អង្គការ UN Women |
| 21116 | អង្គការ UNAIDS (The Joint United Nations Program on HIV and AIDS) |
| 21117 | អង្គការ UNCOHCHR ( United Nations Cambodia Office of the High Commissioner for Human Rights) |
| 21118 | អង្គការ UNDP (United Nations Development Program) |

| | |
|---|---|
| 21119 | អង្គការ UNESCO (United Nations Educational, Scientific and Cultural Organization) |
| 21120 | អង្គការ UNFPA (United Nations Population Fund) |
| 21121 | អង្គការ UNIDO (United Nations Industrial Development Organization) |
| 21122 | អង្គការ UNODC (United Nations Office on Drugs and Crime) |
| 21123 | អង្គការ UNOPS (United Nations Office for Project Services) |
| 21124 | កម្មវិធីស្បៀងអាហារពិភពលោក (WFP) |
| 21125 | អង្គការសុខភាពពិភពលោក (WHO) |
| 21126 | មូលនិធិសកល (Global Fund) |
| 21127 | សម្ព័ន្ធសកលដើម្បីវ៉ាក់សាំង និងការផ្តល់ថ្នាំបង្ការ (GAVI) |
| 212 | ដៃគូអភិវឌ្ឍន៍ទ្វេភាគី (Bilateral Development Partners) |
| 21201 | សាធារណរដ្ឋប្រជាមានិតចិន (China) |
| 21202 | ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) |
| 21203 | សាធារណរដ្ឋឥណ្ឌា (India) |
| 21204 | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |
| 21205 | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋកូរ៉េ (KOICA) |
| 21206 | ម៉ាឡេស៊ី (Malaysia) |
| 21207 | ព្រះរាជាណាចក្រថៃ (Thailand) |
| 21208 | សាធារណរដ្ឋសង្គមនិយមវៀតណាម (Vietnam) |
| 21209 | ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) |
| 21210 | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) |
| 21211 | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ប្រចាំនៅកម្ពុជា (AFD) |
| 21212 | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) |
| 21213 | កាណាដា (Canada) |
| 21214 | ញូហ្សីលែន (New Zealand) |
| 21215 | ស្វីសហ្សីលែន (Switzerland) |
| 22 | មូលនិធិទ្រទ្រង់ថវិកា |
| 221 | ដៃគូអភិវឌ្ឍន៍ពហុភាគី |
| 22101 | ធនាគារពិភពលោក (WB) |
| 22102 | ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) |
| 22103 | សហភាពអឺរ៉ុប (EU) |
| 22104 | អង្គការ UNICEF (United Nation Children's Fund ) |
| 22105 | អង្គការ UNCDF (United Nation Capital Development Fund ) |

| | |
|---|---|
| 222 | ដៃគូអភិវឌ្ឍន៍ទ្វេភាគី |
| 22201 | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |
| 22202 | ទីភ្នាក់ងារស៊ុយអែដសម្រាប់សហប្រតិបត្តិការនិងអភិវឌ្ឍន៍អន្តរជាតិ (SIDA) |
| 3 | ឥណទានសម្បទាន (Loan) |
| 31 | មូលនិធិពិសេស (Special Fund) |
| 311 | ដៃគូអភិវឌ្ឍន៍ពហុភាគី (Multilateral Development Partners) |
| 31101 | ធនាគារពិភពលោក (WB) |
| 31102 | ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) |
| 31103 | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) |
| 31104 | ធនាគារវិនិយោគអឺរ៉ុប (EIB) |
| 31105 | មូលនិធិអូប៉ិចសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (OFID) |
| 31106 | ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) |
| 31107 | មូលនិធិអភិវឌ្ឍន៍ណ័រឌីក (NDF) |
| 31108 | មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) |
| 31109 | មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIF) |
| 312 | ដៃគូអភិវឌ្ឍន៍ទ្វេភាគី (Bilateral Development Partners) |
| 31201 | សាធារណរដ្ឋប្រជាមានិតចិន (China) |
| 31202 | ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) |
| 31203 | សាធារណរដ្ឋឥណ្ឌា (India) |
| 31204 | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |
| 31205 | មូលនិធិសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៃសាធារណរដ្ឋកូរ៉េ (EDCF) |
| 31206 | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ប្រចាំនៅកម្ពុជា (AFD) |
| 31207 | ម៉ាឡេស៊ី (Malaysia) |
| 31208 | ព្រះរាជាណាចក្រថៃ (Thailand) |
| 31209 | សាធារណរដ្ឋសង្គមនិយមវៀតណាម (Vietnam) |
| 32 | មូលនិធិទ្រទ្រង់ថវិកា (Budget Support) |
| 321 | ដៃគូអភិវឌ្ឍន៍ពហុភាគី (Multilateral Development Partners) |
| 32101 | ធនាគារពិភពលោក (WB) |
| 32102 | ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) |
| 322 | ដៃគូអភិវឌ្ឍន៍ទ្វេភាគី (Bilateral Development Partners) |
| 32201 | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |